រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

007KH01A-01

របៀបបង្កើតសាវ័ក



កូនស្បៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៧

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

យោបល់ស្នើជូនសំរាប់ការប្រើមេរៀននេះ

ជូនអត្ថបទសិក្សាម្តងមួយទៅអ្នកជឿថ្មី ។ អោយពួកគេសិក្សានៅផ្ទះសិន រួចអោយពួកគេមកជួបជាមួយអ្នកជាក្រុម បើអាចធ្វើបាន ។ មេរៀននេះ មានអត្ថបទសិក្សាចំនួនប្រាំពីរ ហើយអត្ថបទនិមួយៗនឹងជួយពួកគេអោយអាចអនុវត្តតាមសេចក្តីបង្គាប់ជាគ្រឹះមួយរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត ដែលមានដាក់ជូនជាបន្តបន្ទាប់ទៅនេះ ។ (ដើម្បីអាចជួយដល់ការបង្កើតសាវ័ក សេចក្តីបង្គាប់ទាំងនេះត្រូវបានសង្ខេបជាសេចក្តីបង្គាប់សំខាន់ៗចំនួន ៧) ។ សេចក្តីបង្គាប់ផ្សេងៗទៀតរបស់ព្រះអម្ចាស់ ក៏បញ្ជាក់ពីសេចក្តីសំខាន់ប្រហែលគ្នានឹងសេចក្តីបង្គាប់ទាំងប្រាំពីរនោះដែរ ។

- **កែប្រែចិត្តគំនិត** និង**ជឿ** ដើម្បីអោយព្រះជាម្ចាស់លើកលែងទោសអំពើបាប និងដើម្បីអោយបានទទួលព្រះវិញ្ញាណដ៏-វិសុទ្ធ (ដែលធ្វើអោយយើងដឹងថាព្រះយេស៊ូជាអ្នកណា ដឹងពីកិច្ចការដែលព្រះអង្គធ្វើដើម្បីយើង និងដឹងថាយើងត្រូវដើរតាមព្រះអង្គដោយជំនឿ និងដោយស្តាប់បង្គាប់) ។

កិច្ចការដែលត្រូវអនុវត្ត

- ប្រើរូបភាពបំភ្លឺ ដើម្បីនិយាយប្រាប់គ្រួសារ និងមិត្តភក្តិរបស់អ្នកអំពីរបៀបដែលព្រះយេស៊ូគ្រាស់ហៅសិស្សរបស់ទ្រង់ ។
- ផ្សាយដំណឹងល្អប្រាប់មិត្តភក្តិរបស់អ្នក ហើយជួយបងប្អូនដែលជឿថ្មីលើព្រះគ្រីស្តរបស់អ្នក អោយធ្វើតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះអង្គ ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

© Project WorldReach © SEAN

សូមទន្ទេញ

«ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ "ចូរនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយប្រកាសដំណឹងល្អដល់មនុស្សលោកទាំងអស់" ចុះ » ។ (ម៉ាកុស ១៦:១៥)

នៅពេលដែលអ្នកផ្សព្វផ្សាយដំណឹងល្អ សូមនិយាយរៀបរាប់ពីចំណុចទាំងបីរបស់ដំណឹងល្អនេះ :

១- ជីវិត ការអស្ចារ្យ និងសេចក្តីបង្រៀនរបស់ព្រះយេស៊ូគ្រីស្ត ។

២- ព្រះយេស៊ូសុគតដើម្បីលោះយើងពីបាប ហើយមានព្រះជន្មរស់ឡើងវិញ ដើម្បីប្រទានជីវិតអស់កល្បដល់យើង ។

៣- ការចាំបាច់ត្រូវតែកែប្រែចិត្តគំនិត ជឿលើព្រះអម្ចាស់យេស៊ូគ្រីស្ត និងទទួលពិធីជ្រមុជទឹក ដើម្បីអោយព្រះជាម្ចាស់លើកលែងទោសយើងអោយរួចពីបាប និងដើម្បីទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ។

- **ទទួលពិធីជ្រមុជទឹក** (ហើយត្រូវរស់នៅដោយមានជីវិតថ្មីស្របតាមអត្ថន័យរបស់ពិធីជ្រមុជទឹក ។ ត្រូវដឹងថាព្រះ-វិញ្ញាណដ៏វិសុទ្ធជានរណា ហើយព្រះអង្គធ្វើកិច្ចការអ្វីខ្លះសំរាប់យើង) ។

- **ស្រឡាញ់**ព្រះជាម្ចាស់ អ្នកជឿឯទៀត ក្រុមគ្រួសារ និងអ្នកជិតខាងរបស់យើង ព្រមទាំងសត្រូវរបស់យើងទៀតផង ។ (យើងត្រូវធ្វើកិច្ចការបំរើខ្លះ ដែលបង្ហាញពីសេចក្តីស្រឡាញ់របស់យើងដោយការប្រព្រឹត្ត) ។

- ចូលរួម**ធ្វើពិធីកាច់នំប៉័ង**ដោយទៀងទាត់ (និងត្រូវរួមចិត្តគំនិតជាមួយព្រះគ្រីស្ត និងក្រុមជំនុំរបស់ព្រះអង្គជាប់ជានិច្ចតាមអត្ថន័យរបស់ពិធីកាច់នំប៉័ង) ។

- **អធិស្ឋាន** និងរិះគិតពិចារណាពី**ព្រះបន្ទូលព្រះជាម្ចាស់**រាល់ថ្ងៃដោយមានជំនឿរស់ និងសកម្ម(ហើយទទួលផលប្រយោជន៍ពីឯកសិទ្ធិដ៏ធំ ដែលជាការចូលទៅជិតព្រះជាម្ចាស់ដ៏វិសុទ្ធបំផុត ដោយសារព្រះនាមរបស់ព្រះយេស៊ូ) ។

© Project WorldReach © SEAN

- **ចែកចាយ** ឬ **ថ្វាយដង្វាយដប់ភាគរយ** (ដោយថ្វាយរបស់ទ្រព្យ ពេលវេលា សមត្ថភាពរបស់យើង ក្នុងឋានៈជាអ្នកចាត់ចែងលើអ្វីៗគ្រប់យ៉ាងដែលព្រះជាម្ចាស់ប្រទានដល់យើង ដោយស្មោះត្រង់ និងខ្សាហ៍ព្យាយាម) ។
- **បង្កើតសាវ័ក** (**ផ្សាយដំណឹងល្អ**ពីព្រះគ្រីស្ត និង**បង្រៀន**អ្នកដទៃអោយស្តាប់បង្គាប់ព្រះអម្ចាស់ តាមរយៈពាក្យសំដី និងគំរូរបស់យើង) ។

អត្ថបទសិក្សានិមួយៗមានរូបភាព ដែលសំរាប់ធ្វើអោយអ្នកសិក្សាចាប់អារម្មណ៍ពីមេរៀន ។ សូមទុកអោយពួកអ្នកសិក្សាបញ្ចេញយោបល់អំពីន័យរបស់រូបភាពសិន មុននឹងចាប់ផ្តើមសិក្សាមេរៀនណាមួយ ។

ហេតុអ្វីបានជាលោកពេត្រុសលុតជង្គង់ នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់យេស៊ូគ្រីស្តនៅក្នុងទូក ?

ចាប់ពីពេលនោះទៅ តើលោកពេត្រុសត្រូវ «នេសាទ»អ្វីវិញ ?

ព្រះអម្ចាស់យេស៊ូគ្រីស្តបង្គាប់សិស្សរបស់ព្រះអង្គ អោយដើរតាមព្រះអង្គ ដោយធ្វើពលិកម្មគ្រប់យ៉ាង ដោយធ្វើតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះអង្គ និងដោយស្រឡាញ់គ្នាទៅវិញទៅមក ។

តើអ្នកនឹងជួយអ្នកណាឱ្យក្លាយទៅជាសាវ័កស្មោះត្រង់របស់ព្រះ-គ្រីស្ត ? សូមសរសេរឈ្មោះសាច់ញាតិ ឬ មិត្តភក្តិពីរបីនាក់ដែលអ្នកនឹងជួយ :

© Project WorldReach © SEAN

អត្ថន័យរបស់រូបភាពទាំងឡាយ

- ព្រះអម្ចាស់យេស៊ូគ្រីស្តបង្ហាញព្រះហស្តរបស់ព្រះអង្គ អោយពួកសាវ័ករបស់ព្រះអង្គមើលនៅថ្ងៃដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ (លូកា ២៤:៣៦-៤៤) ។
- អណ្តាតភ្លើងនៅលើក្បាលពួកសាវ័ក នៅបុណ្យថៃទីហាសិប (កិច្ចការ ២) ។
- លោកសង្ឃដែលធ្វើដំណើរតាមផ្លូវទៅក្រុងយេរីខូ ដើរវាងពីបុរសដែលត្រូវរបួស (ដកស្រង់ពីប្រស្នាអំពីអ្នកស្រុកសាម៉ារីដែលមានចិត្តសប្បុរស នៅក្នុងបទគម្ពីរលូកា ១០:២៥-៣៧) ។
- យើងជាមែក ដែលជាប់នឹងដើមទំពាំងបាយជូរ និងដែលបង្កើតផលផ្លែ (យ៉ូហាន ១៥:១-១៧) ។
- នៅពេលដែលអ្នកទារពន្ធម្នាក់អធិស្ឋាននៅក្នុងព្រះវិហារ ទូលសូមអោយព្រះជាម្ចាស់លើកលែងទោសអោយរួចពីបាបនោះ មានអ្នកខាងគណៈផារីស៊ីដែលកាន់ក្រឹត្យវិន័យម្នាក់អធិស្ឋានអួតខ្លួនឯង (លូកា ១៨:៩-១៤) ។

ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំអោយវិន័យថ្មីដល់អ្នករាល់គ្នា គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក ។ អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ ។ បើអ្នកស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជាដឹងថា អ្នករាល់គ្នាពិតជាសាវ័ករបស់ខ្ញុំមែន» ។ (យ៉ូហាន ១៣:៣១-៣៥)

ក្រោយពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញហើយ :

សាវ័កទាំងដប់មួយរូប នាំគ្នាធ្វើដំណើរទៅស្រុកកាលីឡេ ហើយឡើងទៅលើភ្នំដែលព្រះយេស៊ូបានប្រាប់អោយគេទៅ ។ កាលគេបានឃើញព្រះអង្គ គេក្រាបថ្វាយបង្គំ ប៉ុន្តែ មានអ្នកខ្លះនៅសង្ស័យ ។ ព្រះយេស៊ូយាងចូលមកជិតគេ ហើយមានព្រះបន្ទូលថា៖ «ខ្ញុំបានទទួលគ្រប់អំណាច ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី ។ ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកអោយគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថៃ រហូតដល់អវសានកាលនៃពិភពលោក» ។ (ម៉ាថាយ ២៨:១៦-២០)

- នៅពេលដែលយុវជនអ្នកមានម្នាក់ មិនព្រមលះបង់ទ្រព្យសម្បត្តិខ្លួនដើម្បីដើរតាមព្រះយេស៊ូ ព្រះអង្គមានព្រះបន្ទូលថា « *សត្វអូដ្ឋមួយចូលតាមប្រហោងម្ជុលបាន ស្រួលជាងអ្នកមានម្នាក់ចូលទៅក្នុងព្រះរាជ្យរបស់ស្ថានបរមសុខ*» (លូកា ១៨:១៨-២៥) ។

- បន្ទាប់ពីព្រះយេស៊ូបានធ្វើការអស្ចារ្យ ដើម្បីអោយលោកពេត្រុសចាប់ត្រីបានច្រើនមក ព្រះអម្ចាស់ត្រាស់ហៅគាត់អោយធ្វើជាអ្នកនេសាទមនុស្សវិញ (យ៉ូហាន ២១) ។

នៅចុងបញ្ចប់អត្ថបទសិក្សានិមួយៗ មានពាក្យថា :

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

ដែរ ។ ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលទៅលោកស៊ីម៉ូនថា៖ «កុំខ្លាចអី ! ពីពេលនេះទៅមុខ អ្នកនឹងនេសាទមនុស្សវិញ » ។

(លូកា ៥:១-១១)

បន្ទាប់មក ព្រះយេស៊ូយាងឡើងទៅលើភ្នំ ។ ព្រះអង្គបានត្រាស់ហៅអស់អ្នកដែលព្រះអង្គសព្វព្រះហឫទ័យជ្រើសរើស ហើយអ្នកទាំងនោះក៏ចូលមកគាល់ព្រះអង្គ ។ ព្រះអង្គតែងតាំងសាវ័កដប់-ពីររូបអោយគេនៅជាមួយព្រះអង្គ និងដើម្បីចាត់គេអោយទៅប្រកាសដំណឹងល្អ ទាំងអោយគេមានអំណាចដេញអារក្សថែមទៀតផង ។

ព្រះអង្គបានតែងតាំងអ្នកដប់ពីររូបនេះ គឺស៊ីម៉ូនដែលទ្រង់ដាក់ឈ្មោះថា ពេត្រុសសិលា យ៉ាកុបជាកូនរបស់លោកសេបេដេ និងយ៉ូហានជាប្អូនរបស់គាត់ ដែលព្រះយេស៊ូដាក់ឈ្មោះថា «បោណើកែស » ប្រែថា "អ្នកដែលមានចិត្តខ្លាំងដូចផ្គរលាន់" អន់ដ្រេ ភីលីព បាថូឡូមេ ម៉ាថាយ ថូម៉ាស យ៉ាកុបជាកូនអាល់ផាយ ថាដេ ស៊ីម៉ូនជាអ្នកជាតិនិយម និងយូដាសអ៊ីស្ការីយ៉ុតជាអ្នកក្បត់ព្រះអង្គ ។

(ម៉ាកុស ៣:១៣-១៩)

បង្កើតសាវ័កថ្វាយព្រះយេស៊ូគ្រីស្ត

...ព្រះយេស៊ូគង់បង្រៀនបណ្តាជនពីក្នុងទូក ។ លុះព្រះអង្គ បង្រៀនគេចប់ហើយ ទ្រង់មានព្រះបន្ទូលទៅកាន់លោកស៊ីម៉ូន ថា÷ «ចូរបង្ហួសទូកទៅទីកជ្រៅ រួចនាំគ្នាទម្លាក់អួនចុះ» ។

លោកស៊ីម៉ូនតបទៅព្រះយេស៊ូវិញថា÷ «លោកគ្រូ ! យើងខ្ញុំបាន អួសអួនពេញមួយយប់ហើយ អត់បានត្រីសោះ ប៉ុន្តែ បើលោកគ្រូ មានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ»។ គេក៏ទម្លាក់អួនទៅក្នុងទឹក ជាប់ត្រីយ៉ាងច្រើនស្ទើរតែធ្លាយអួន ។ គេបក់ដៃហៅមិត្តភក្តិ ដែលនៅក្នុងទូកមួយទៀតអោយមកជួយ ។ ពួកនោះមកដល់ជួយចាប់ត្រីដាក់ពេញទូកទាំងពីរស្ទើរតែនឹងលិច ។

ពេលលោកស៊ីម៉ូនពេត្រុសសិលាឃើញដូច្នោះ គាត់ក្រាបទៀប ព្រះបាទាព្រះយេស៊ូទូលព្រះអង្គថា÷«ព្រះអម្ចាស់អើយ សូមយាង អោយឆ្ងាយពីទូលបង្គំទៅ ព្រោះទូលបង្គំជាមនុស្សបាប» ។ លោកស៊ីម៉ូននិយាយដូច្នេះ ព្រោះគាត់ និងអស់អ្នកដែលនៅ ជាមួយភ័យស្ញប់ស្ញែងជាខ្លាំង នៅពេលបានឃើញត្រីច្រើនយ៉ាង នេះ ។ រីងលោកយ៉ាកុប និង លោកយ៉ូហានជាកូនលោក សេបេដេដែលនេសាទរួមជាមួយលោកស៊ីម៉ូន ក៏មានចិត្តដូច្នោះ

សូមចុះហត្ថលេខា និងដាក់ថ្ងៃខែ នៅពេលដែលអ្នកបានពិនិត្យ ឃើញថាអ្នកសិក្សាបាន :

- ឆ្លើយសំណួរត្រឹមត្រូវ ។
- ទន្ទេញខគម្ពីរចាំស្មាត់ ។
- ធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ :
  - ធ្វើតាមសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ ។
  - និយាយរឿងក្នុងព្រះគម្ពីរ ប្រាប់ដល់ក្រុមគ្រួសាររបស់ខ្លួន ដោយប្រើរូបភាពបំភ្លឺ ។

(សូមចុះហត្ថលេខា តែនៅពេលដែលអ្នកឃើញលទ្ធផលទាំងអស់នេះហើយ) ។

សន្លឹកពត៌មានសំរាប់គ្រូបង្ហាត់

គ្រូបង្ហាត់ _____

ក្រុមជំនុំ ឬ ក្រុម _____

សូមសរសេរឈ្មោះអ្នកសិក្សារបស់អ្នក នៅក្នុងបញ្ជីខាងក្រោមនេះ ។ នៅពេលដែលអ្នកអោយអត្ថបទសិក្សាណាមួយទៅអ្នកសិក្សាណាម្នាក់ សូមគូររង្វង់ជុំវិញលេខរបស់អត្ថបទសិក្សានោះ ។ សូមគូរសញ្ញា «×» នៅក្នុងរង្វង់នោះ នៅពេលដែលអ្នកសិក្សាបានធ្វើលំហាត់រួចហើយ ។

អ្នកសិក្សា	អត្ថបទសិក្សា
_____	១ ២ ៣ ៤ ៥ ៦ ៧
_____	១ ២ ៣ ៤ ៥ ៦ ៧
_____	១ ២ ៣ ៤ ៥ ៦ ៧
_____	១ ២ ៣ ៤ ៥ ៦ ៧
_____	១ ២ ៣ ៤ ៥ ៦ ៧
_____	១ ២ ៣ ៤ ៥ ៦ ៧
_____	១ ២ ៣ ៤ ៥ ៦ ៧

អត្ថបទសិក្សា ទី ៧

ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត



© Project WorldReach © SEAN

អត្ថបទសិក្សា ទី ១

ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត



កិច្ចការដែលត្រូវអនុវត្ត

- ចូរដាក់ដង្វាយស្មគ្រចិត្ត និងដង្វាយដប់ភាគរយ ហើយដាក់ដង្វាយជាការជួយ និងជាពេលវេលា ។ល។...ដោយអំណរ និងដោយសប្បុរស ហើយបង្រៀនក្រុមគ្រួសាររបស់អ្នកឱ្យធ្វើដូច្នេះដែរ ។ យើងដាក់ដង្វាយសំរាប់ជួយកិច្ចការក្រុមជំនុំ កិច្ចការគ្រីស្តទូត និងសំរាប់ជួយអ្នកខ្វះខាត ។
- ប្រើរូបភាពបំភ្លឺ ដើម្បីនិយាយប្រាប់ក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នកពីប្រស្នាស្តីអំពីអ្នកមាន ដែលឆោតល្ងង់ និងរឿងបុរសដែលមិនដើរតាមព្រះយេស៊ូគ្រីស្ត ដោយសារតែទ្រព្យសម្បត្តិរបស់គាត់ ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

នៅថ្ងៃដដែលនោះ មានសាវ័កពីរនាក់ធ្វើដំណើរឆ្ពោះទៅភូមិ-អេម៉ាអ៊ូស ចម្ងាយប្រមាណដប់មួយគីឡូម៉ែត្រពីក្រុងយេរូសាឡឹម។ គេនិយាយគ្នាអំពីហេតុការណ៍ទាំងប៉ុន្មាន ដែលកើតមាន ។

នៅពេលដែលគេកំពុងតែពិភាក្សាគ្នា ព្រះយេស៊ូយាងមកជិតគេ ហើយធ្វើដំណើរជាមួយគេទៅ ។ គេឃើញព្រះយេស៊ូផ្ទាល់នឹងភ្នែក តែគេមិនអាចស្គាល់ព្រះអង្គបានឡើយ ។ ព្រះយេស៊ូមានព្រះបន្ទូលសួរគេថា៖ «អ្នករាល់គ្នាដើរបណ្តើរ ជជែកគ្នាបណ្តើរ តើនិយាយគ្នាអំពីរឿងអ្វីហ្នឹង ? » ។

គេក៏ឈប់ដើរ ឈរស្ងៀម មានទឹកមុខស្រងូត ។ ម្នាក់ឈ្មោះក្លេអូប៉ាសទូលព្រះអង្គថា៖«ប្រជាជនទាំងអស់នៅក្រុងយេរូសាឡឹមដឹងហេតុការណ៍ដែលកើតឡើង...ម្តេចក៏លោកមិនដឹង ? » ។ ព្រះអង្គសួរទៅគេថា៖ «តើរឿងអ្វី ? » ។

គេទូលឆ្លើយថា៖ «គឺរឿងលោកយេស៊ូជាអ្នកភូមិណាសារ៉ែត ។ ព្រះជាម្ចាស់ និង ប្រជាជនទាំងមូលទទួលស្គាល់ថាលោកជាព្យាការីមានឫទ្ធានុភាពក្នុងគ្រប់កិច្ចការដែលលោកបានធ្វើ និងគ្រប់ពាក្យសំដីដែលលោកបានថ្លែង ។ ពួកនាយកបូជាចារ្យ និង

ស្ត្រីមេម៉ាយក្រីក្រនេះ បានដាក់ប្រាក់ក្នុងហិបច្រើនជាងគេទាំងអស់ ដ្បិតពួកអ្នកទាំងនោះយកប្រាក់សំណល់របស់ខ្លួនមកដាក់ ។ រីងស្ត្រីមេម៉ាយនេះវិញ ទោះបីនាងក្រីក្រយ៉ាងណាក៏ដោយ ក៏នាងបានយកប្រាក់ដែលនាងត្រូវការជាចាំបាច់មកដាក់ដែរ គឺប្រាក់ទាំងប៉ុន្មាន ដែលនាងមានសំរាប់ចិញ្ចឹមជីវិត » ។

(ម៉ាកុស ១២:៤១-៤៤)

ព្រះយេស៊ូគ្រីស្តវាយតំលៃដង្វាយ ដែលយើងថ្វាយ យោងទៅតាមប្រាក់ដែលនៅសល់ ក្រោយការដាក់ដង្វាយ ! ។ ព្រះជាម្ចាស់នឹងប្រទានពរអោយយើង បើសិនជា :

- ☐ យើងដាក់ដង្វាយតែអ្វីដែលយើងនៅសល់ ក្រោយពីយើងចាយដើម្បីខ្លួនឯងសិន ។
- ☐ យើងថ្វាយដោយសេចក្តីស្រឡាញ់ និងដោយអំណរ ។

សូមទន្ទេញ

«ចូរធ្វើអំណោយដល់អ្នកដទៃ នោះព្រះជាម្ចាស់នឹងប្រទានអំណោយដល់អ្នករាល់គ្នាដែរ ទ្រង់នឹងប្រទានមកយ៉ាងបរិបូណ៌ហូរហៀរ ។ ព្រះជាម្ចាស់នឹងវាល់អោយអ្នកតាមរង្វាល់ ដែលអ្នកវាល់អោយអ្នកដទៃ » ។ (លូកា ៦:៣៨)

បំណងចង់ប្រមូលអោយបានអ្វីៗជាច្រើនជារបស់ខ្លួន អាចធ្វើឱ្យយើងភ្លេចពីព្រះគ្រីស្ត ។ ពួកសាវ័កលើកទឹកចិត្តយើងអោយដាក់ជង្វាយ តែមិនមែនដោយសារយើងមានកាតព្វកិច្ចត្រូវតែដាក់នោះទេ តែដោយសារយើងស្ម័គ្រចិត្តដាក់ ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នកដែលធ្វើអំណោយដោយចិត្តអំណរ ។ ព្រះអង្គប្រទានពរដល់អ្នកដែលដាក់ជង្វាយដោយសប្បុរស (២ កូរិនថូស ៩:៦-៩) ។

តើអ្នកចេះដាក់ជង្វាយដោយចិត្តអំណរដែរឬទេ ? សូមសរសេរពីផែនការរបស់អ្នក :

_____

_____

_____

ព្រះយេស៊ូគង់នៅមុខហិបតង្វាយ ព្រះអង្គទតមើលរបៀបដែលបណ្តាជនយកប្រាក់មកដាក់ក្នុងហិបនោះ ។ អ្នកមានច្រើននាក់ដាក់ប្រាក់ជាច្រើន ។ មានស្ត្រីមេម៉ាយក្រីក្រម្នាក់មកដល់ នាងយកប្រាក់ពីរសេនជាចំនួនជិតិចតួចបំផុត ដាក់ក្នុងហិបតង្វាយនោះដែរ ។ ព្រះយេស៊ូត្រាស់ហៅពួកសាវ័កមក ហើយមានព្រះ-បន្ទូលទៅគេថា÷ «ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាបានដឹងច្បាស់ថា

ពួកមន្ត្រីរបស់យើងបានបញ្ជូនលោកទៅឱ្យគេកាត់ទោសប្រហារជីវិត ហើយគេឆ្កាងលោកផង ។ យើងបានសង្ឃឹមថា លោកនេះហើយដែលនឹងរំដោះជនជាតិអ៊ីស្រាអែល ។ តែហេតុការណ៍ទាំងនោះបានកន្លងផុតទៅបីថ្ងៃហើយ ។

... មានស្ត្រីខ្លះក្នុងចំណោមពួកយើង បានធ្វើអោយយើងឆ្ងល់យ៉ាងខ្លាំង គឺនាងនាំគ្នាទៅផ្នូរតាំងពីព្រលឹម តែមិនបានឃើញសពលោកទេ ។ នាងត្រឡប់មកវិញ រៀបរាប់ថានាងបានឃើញទេវទូតមកប្រាប់ថាលោកមានជីវិតរស់...» ។

ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា÷ «មនុស្សខ្លះប្រាជ្ញាអើយ ! អ្នករាល់គ្នាមិនងាយជឿពាក្យទាំងប៉ុន្មាន ដែលពួកព្យាការីបានថ្លែងសោះ ! ព្រះគ្រីស្តត្រូវតែរងទុក្ខលំបាកបែបនេះសិន មុននឹងចូលទៅទទួលសិរីរុងរឿងរបស់ព្រះអង្គ » ។

បន្ទាប់មក ព្រះយេស៊ូបកស្រាយសេចក្តីដែលមានចែងទុកអំពីព្រះអង្គ នៅក្នុងគម្ពីរទាំងមូល ចាប់ពីគម្ពីរលោកម៉ូសេរហូតដល់គម្ពីរព្យាការីទាំងអស់...

ព្រះអង្គគង់រួមតុជាមួយគេ ហើយយកនំប៉័ងមកកាន់ អរព្រះគុណ
ព្រះជាម្ចាស់ រួចកាច់ប្រទានអោយគេ ។ ពេលនោះ ភ្នែកគេបាន
ភ្លឺឡើង មើលព្រះអង្គស្គាល់ ប៉ុន្តែ ព្រះអង្គបាត់ពីមុខគេទៅ ។
គេនិយាយគ្នាថា៖ «កាលព្រះអង្គមានព្រះបន្ទូលមកកាន់យើង
ព្រមទាំងបកស្រាយគម្ពីរអោយយើងស្តាប់នៅតាមផ្លូវ យើងមាន
ចិត្តរំភើបយ៉ាងខ្លាំង ! » ។

គេក៏ក្រោកឡើង វិលត្រឡប់ទៅក្រុងយេរូសាឡឹមវិញភ្លាម ឃើញ
ក្រុមសាវ័កទាំងដប់មួយនាក់នៅជុំគ្នាជាមួយពួកគេឯទៀតៗ គេ
ប្រាប់អ្នកទាំងពីរថា៖ «ព្រះអម្ចាស់មានព្រះជន្មរស់ឡើងវិញពិត
ប្រាកដមែន ហើយទ្រង់បានបង្ហាញខ្លួនអោយស៊ីម៉ូនឃើញ ! » ។

នៅពេលសាវ័កទាំងពីរនាក់កំពុងតែនិយាយរៀបរាប់ ព្រះអម្ចាស់
យាងមកគង់នៅកណ្តាលចំណោមសាវ័កទាំងអស់ ហើយមាន
ព្រះបន្ទូលថា៖ «សូមអោយអ្នករាល់គ្នាប្រកបដោយសេចក្តីសុខ-
សាន្ត » ។ គេភ័យតក់ស្លុត ញ័ររន្ធត់យ៉ាងខ្លាំង ព្រោះស្មានថា
ខ្មោចលង ។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ **"ហេតុអ្វីបានជាអ្នក
រាល់គ្នារន្ធត់ចិត្តដូច្នេះ ? ម្តេចក៏អ្នករាល់គ្នានៅសង្ស័យ ?** ចូរ
មើលដៃជើងខ្ញុំ គឺពិតជាខ្ញុំមែន ! ចូរស្ទាបមើល៍ ខ្មោចគ្មានសាច់

ទទួលបានយ៉ាងច្រើន លើសលប់នៅពេលឥឡូវនេះ ព្រមទាំងមាន
ជីវិតអស់កល្បជានិច្ចនៅពេលខាងមុខថែមទៀតផង » ។

(លូកា ១៨:១៨-៣០)

ហេតុអ្វីបានជាព្រះគ្រីស្តថា បុរសអ្នកមាននោះជា «មនុស្សឆោត
ល្ងង់ » ?

_____

_____

តើបុរសអ្នកមានម្នាក់ទៀត ស្រឡាញ់អ្វីខ្លាំងជាងព្រះយេស៊ូ ?

_____

_____

ហេតុអ្វីបានជាអ្នកមានពិបាកនឹងចូលទៅនគរស្ថានបរមសុខ ?

_____

_____

តើទ្រព្យសម្បត្តិរបស់អ្នក អាចនាំអោយអ្នកមានគ្រោះថ្នាក់ដែរឬទេ ?

_____

© Project WorldReach © SEAN

ព្រះយេស៊ូឮដូច្នេះ ទ្រង់មានព្រះបន្ទូលថា÷ «នៅសល់កិច្ចការមួយទៀត ដែលលោកមិនទាន់ធ្វើ គឺត្រូវយកអ្វីៗទាំងអស់ដែលលោកមានទៅលក់ ហើយចែកអោយជនក្រីក្រ ។ ធ្វើដូច្នេះ លោកនឹងបានសម្បត្តិសួគ៌ រួចសឹមអញ្ជើញមកតាមខ្ញុំចុះ » ។ ពេលនាម៉ឺននោះឮដូច្នេះ គាត់ព្រួយចិត្តយ៉ាងខ្លាំង ដ្បិតគាត់ជាអ្នកមានស្តុកស្តម្ភ ។ កាលព្រះយេស៊ូឃើញគាត់ព្រួយចិត្ត ព្រះអង្គមានព្រះបន្ទូលថា÷ «អ្នកមានពិបាកនឹងចូលទៅក្នុងព្រះរាជ្យព្រះជាម្ចាស់ណាស់ សត្វអូដ្ឋចូលតាមប្រហោងម្ជុល ងាយជាងអ្នកមានចូលទៅក្នុងព្រះរាជ្យព្រះជាម្ចាស់ទៅទៀត » ។

អស់អ្នកដែលឮព្រះបន្ទូលរបស់ព្រះអង្គពោលឡើងថា÷ «បើដូច្នេះ តើអ្នកណាអាចទទួលការសង្គ្រោះបាន ? » ។

ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយថា÷ «ការអ្វីដែលមនុស្សធ្វើពុំកើត ព្រះជាម្ចាស់ធ្វើកើតទាំងអស់ » ។ លោកពេត្រុសសិលាទូលព្រះអង្គថា÷ «ព្រះអង្គទតឃើញស្រាប់ហើយ អ្វីៗដែលយើងខ្ញុំមាន យើងខ្ញុំបានលះបង់ចោលទាំងអស់ ហើយមកតាមព្រះអង្គ » ។ ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា÷ «ខ្ញុំសុំប្រាប់ឱ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាលះបង់ផ្ទះសម្បែង ប្រពន្ធ កូន ឪពុកម្តាយ និងបងប្អូន ដោយយល់ដល់ព្រះរាជ្យព្រះជាម្ចាស់ អ្នកនោះនឹងគ្មានឆ្គឹងដូចខ្ញុំទេ » ។ ព្រះអង្គមានព្រះបន្ទូលដូច្នោះហើយ ក៏បង្ហាញព្រះហស្ត និងព្រះបាទាអោយគេឃើញ ។

(លូកា ២៤:១៣-៥៣)

នៅក្នុងវគ្គព្រះគម្ពីរនេះ សិស្សរបស់ព្រះយេស៊ូភ័យតក់ស្លុត ហើយញ័ររន្ធត់យ៉ាងខ្លាំង ។

តើព្រះយេស៊ូមានព្រះបន្ទូលពន្យល់ពួកគេអំពីការនេះដូចម្តេចខ្លះ ? (សូមមើលឃ្លា នៅក្នុងអត្ថបទ ដែលសរសេរជាអក្សរធំៗ) ។

_____

_____

_____

_____

ចម្លើយ : អំពី «ពួកគេនៅសង្ស័យ និងនៅរន្ធត់ចិត្ត » ហើយ និងអំពី «សេចក្តីដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបង្រៀនគេយ៉ាងច្បាស់លាស់ »។

ព្រះយេស៊ូបង្ហាញថាព្រះអង្គជាព្រះពិត និងជាមនុស្សពិត ដោយមានព្រះជន្មរស់ឡើងវិញ ។

សូមទន្ទេញ

«រីឯសេចក្តីដែលមានកត់ត្រាមកនេះ គឺក្នុងគោលបំណងអោយអ្នករាល់គ្នាជឿថា ព្រះយេស៊ូពិតជាព្រះគ្រីស្ត និងពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយអោយអ្នករាល់គ្នាដែលជឿ មានជីវិតដោយរួមជាមួយព្រះអង្គ » ។ (យ៉ូហាន ២០:៣១)

ខគម្ពីរនេះចែងថា ព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញនេះជាព្រះមេស៊ី និងជាព្រះបុត្រារបស់ _____

បើអ្នកជឿលើព្រះអង្គ តើអ្នកនឹងទទួលបានអ្វី ?

តើអ្នកនៅសង្ស័យ ឬ អ្នកនឹងទទួលជឿ និងថ្វាយជីវិតរបស់អ្នកទៅព្រះយេស៊ូគ្រីស្ត ?

ព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់សេដ្ឋីនោះថា÷ "នែ មនុស្សឆោតល្ងង់អើយ ! យប់នេះយើងនឹងផ្តាច់ជីវិតអ្នកហើយ ដូច្នេះទ្រព្យសម្បត្តិដែលអ្នកបានប្រមូលទុកសំរាប់ខ្លួនអ្នក នឹងបានទៅជារបស់នរណាវិញ ?" » ។

ព្រះយេស៊ូមានព្រះបន្ទូលទៀតថា÷ «អ្នកណាប្រមូលទ្រព្យសម្បត្តិទុកសំរាប់តែខ្លួនឯង ហើយគ្មានសម្បត្តិសួគ៌នៅក្នុងខ្លួន អ្នកនោះប្រៀបបីដូចជាសេដ្ឋីនោះដែរ » ។

(លូកា ១២:១៣-២១)

មាននាម៉ឺនម្នាក់ទូលសួរព្រះយេស៊ូថា÷«លោកគ្រូដ៏សប្បុរសអើយ! តើខ្ញុំត្រូវធ្វើអ្វី ដើម្បីអោយបានទទួលជីវិតអស់កល្បជានិច្ច ទុកជាមតិក ? » ។

ព្រះយេស៊ូមានព្រះបន្ទូលតបថា÷ «ហេតុអ្វីបានជាលោកថា ខ្ញុំសប្បុរសដូច្នេះ ? ក្រៅពីព្រះជាម្ចាស់មួយព្រះអង្គ គ្មាននរណាម្នាក់សប្បុរសឡើយ ។ លោកស្គាល់វិន័យស្រាប់ហើយថា"កុំប្រព្រឹត្តអំពើផិតក្បត់ កុំសម្លាប់មនុស្ស កុំលួចទ្រព្យសម្បត្តិគេ កុំនិយាយកុហកធ្វើអោយគេមានទោស ចូរគោរពមាតាបិតា"» ។ បុរសនោះទូលព្រះយេស៊ូថា÷ «ខ្ញុំបានប្រព្រឹត្តតាមវិន័យទាំងនេះតាំងតែពីក្មេងមក » ។

ចូរធ្វើអំណោយដោយចិត្តអំណរ

ក្នុងចំណោមបណ្តាជន មានបុរសម្នាក់ទូលព្រះយេស៊ូថា÷ «លោកគ្រូ ! សូមលោកប្រាប់បងខ្ញុំឱ្យយកកេរ្តិ៍មរតកមកចែកខ្ញុំផង» ។

ព្រះយេស៊ូមានព្រះបន្ទូលតបទៅបុរសនោះថា÷«តើនរណាបានតែងតាំងខ្ញុំអោយធ្វើជាចៅក្រមចែកទ្រព្យសម្បត្តិរបស់អ្នករាល់គ្នា ?»។ បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅបណ្តាជនថា÷ «ចូរប្រយ័ត្នកុំលោភលន់ចង់បានទ្រព្យសម្បត្តិអោយសោះ ។ ទោះបីមនុស្សមានសម្បត្តិបរិបូណ៌យ៉ាងណាក៏ដោយ ក៏ជីវិតគេមិនអាស្រ័យនៅលើទ្រព្យសម្បត្តិឡើយ » ។

ព្រះអង្គមានព្រះបន្ទូលជាពាក្យប្រស្នាទៅគេថា÷ «មានបុរសម្នាក់ជាសេដ្ឋី ដីធ្លីរបស់គាត់បានភោគផលយ៉ាងបរិបូណ៌ ។ គាត់រិះគិតក្នុងចិត្តថា"ខ្ញុំគ្មានកន្លែងដាក់ភោគផលទាំងអស់របស់ខ្ញុំទេ តើខ្ញុំត្រូវធ្វើដូចម្តេច ?" គាត់គិតទៀតថា"ខ្ញុំត្រូវតែធ្វើយ៉ាងនេះ គឺរុះជង្រុកទាំងប៉ុន្មានរបស់ខ្ញុំចោល ហើយសង់ជង្រុកអោយធំៗជាងរួចខ្ញុំប្រមូលស្រូវ ព្រមទាំងភោគផលទាំងអស់មកដាក់ក្នុងជង្រុកថ្មីនោះ ។ បន្ទាប់មក ខ្ញុំនឹងនិយាយប្រាប់ខ្លួនខ្ញុំថា"ឱ ខ្ញុំអើយ ! មានសម្បត្តិយ៉ាងច្រើនបរិបូណ៌ បំរុងទុកចិញ្ចឹមជីវិត សំរាប់ច្រើនឆ្នាំ ខ្ញុំត្រូវសំរាក គិតតែស៊ីផឹកសប្បាយទៅ !" ។ ប៉ុន្តែ

កិច្ចការដែលត្រូវអនុវត្ត

- សូមឈប់សង្ស័យ ហើយទទួលជឿចុះ ព្រមទាំងថ្វាយជីវិតអ្នកទាំងមូលទៅព្រះគ្រីស្ត និងធ្វើតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះអង្គផង ។
- សូមបំផ្លាញសៀវភៅ ខ្សែកថា របស់អ្វីៗដែលជាប់ទាក់ទងនឹងអំពើអាបធ្មប់ ឬ អបិយ៍ជំនឿ និងរបស់អ្វីៗដែលជាប់ទាក់ទងនឹងសាសនាក្លែងក្លាយ (ព្រះជាម្ចាស់សព្វព្រះហ-ទ័យអោយយើងមានជំនឿស្មោះអស់ពីចិត្ត) ។ ឈប់ជាប់ជំពាក់ទាក់ទងនឹងរបស់ទាំងនោះ ហើយទូលសូមអោយព្រះជាម្ចាស់រំដោះអ្នកអោយរួចពីឥទ្ធិពលអាក្រក់នៃអំពើទាំងអស់នោះ ។
- កែប្រែចិត្តគំនិតពិតប្រាកដ ដោយអនុវត្តដូចតទៅនេះ : សូមទោសមនុស្សដែលអ្នកបានធ្វើខុសលើគេ ជួយអ្នកដែលខ្វះខាត សងរបស់ដែលអ្នកបានលួចទៅអោយម្ចាស់ដើមវិញ បើអ្នកបាននិយាយភូតភរ ត្រូវសារភាព ឬ កែតម្រូវពាក្យអាក្រក់ ដែលអ្នកបាននិយាយពីអ្នកណាម្នាក់ ។ល។ ។

អត្ថបទសិក្សា ទី ៦

ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត



- និយាយប្រាប់ក្រុមគ្រួសារ និង មិត្តភក្តិរបស់អ្នក អំពីរឿងដែលព្រះយេស៊ូលេចមកអោយពួកសិស្សព្រះអង្គឃើញក្រោយពេលដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ ដោយប្រើរូបភាព ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

© Project WorldReach © SEAN

អត្ថបទសិក្សា ទី ២

ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត



កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋាន និងរិះគិតពិចារណាពីវគ្គណាមួយនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់រាល់ថ្ងៃ ហើយបង្រៀនក្រុមគ្រួសាររបស់អ្នកអោយចេះធ្វើដូចនេះដែរ ។
- និយាយប្រាប់ក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នកអំពីប្រស្នាស្តីពីស្ត្រីមេម៉ាយដែលចេះតស៊ូ និងប្រស្នាអំពីអ្នកខាងគណៈផារីស៊ី និងអ្នកទារពន្ធដោយប្រើរូបភាពបំភ្លឺ ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

ព្រះអំណោយទានជាព្រះវិញ្ញាណដ៏វិសុទ្ធ

នៅបុណ្យថ្ងៃទីហាសិប ពួកសាវ័កបានរួមប្រជុំទាំងអស់គ្នា នៅកន្លែងតែមួយ ។ រំពេចនោះស្រាប់តែមានឮស្នរសន្ធឹកពីលើមេឃដូចខ្យល់បក់បោកយ៉ាងខ្លាំងពេញក្នុងផ្ទះដែលគេនៅ ។ ពួកសាវ័កបានឃើញហាក់ដូចជាមានអណ្តាតភ្លើងបែកចេញពីគ្នា ចុះមកសណ្ឋិតលើពួកគេម្នាក់ៗ ។ អ្នកទាំងនោះបានពោរពេញ ដោយព្រះវិញ្ញាណដ៏វិសុទ្ធ ហើយចាប់ផ្តើមនិយាយភាសាផ្សេងៗពីគ្នា តាមព្រះវិញ្ញាណប្រោសប្រទានអោយ ។

ពេលនោះ មានជនជាតិយូដា ជាអ្នកគោរពប្រណិប័តន៍ព្រះ-ជាម្ចាស់ មកពីប្រទេសនានាក្នុងពិភពលោកទាំងមូល ស្នាក់នៅក្រុងយេរូសាឡឹមដែរ ។ ពេលស្នរសន្ធឹកលាន់ឮយ៉ាងខ្លាំងដូច្នោះ មហាជននាំគ្នារត់មកមើល ហើយភ្ញាក់ផ្អើលក្រៃលែង ពីព្រោះម្នាក់ៗបានឮពួកសាវ័កនិយាយភាសារបស់ខ្លួន ។ អ្នកទាំងនោះងឿងឆ្ងល់ខ្លាំងណាស់ គេស្ងើចសរសើរទាំងពោលថា÷ «អ្នកដែលកំពុងនិយាយនេះ សុទ្ធតែជាអ្នកស្រុកកាលីឡេទេតើ ។ ចុះហេតុដូចម្តេចបានជាយើងឮគេនិយាយភាសារបស់យើងរៀងៗខ្លួនទៅ

សូមទន្ទេញ

«ឱព្រះបិតានៃយើងខ្ញុំដែលគង់នៅស្ថានបរមសុខអើយ ! សូមសំដែងព្រះបារមីអោយមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ សូមអោយព្រះរាជ្យព្រះអង្គបានមកដល់ សូមអោយព្រះហឫទ័យរបស់ព្រះអង្គបានសំរេច នៅលើផែនដី ដូចនៅស្ថានបរមសុខដែរ ។ សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ ។ សូមអត់ទោសអោយយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសអោយអស់អ្នកដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ ។ សូមកុំបណ្តោយឱ្យយើងខ្ញុំចាញ់ការល្បួងឡើយ តែសូមរំដោះយើងខ្ញុំអោយរួចពីមារកំណាច » ។

(ម៉ាថាយ ៦:៩-១៣)

© Project WorldReach © SEAN

គ្រីស្តជនត្រូវតែអាន និងរិះគិតពិចារណាពីព្រះបន្ទូលព្រះជាម្ចាស់រាល់ថ្ងៃ ។ ធ្វើដូចនេះ ទើបគេអាចយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សំរាប់ជីវិតគេបាន ។ សូមចាប់ផ្តើមអានសម្ពន្ធមេត្រីថ្មីសិន ដោយអានមួយថ្ងៃមួយវគ្គ ។

តើអ្នកយល់ព្រមអាន និងរិះគិតពិចារណាពីព្រះបន្ទូលព្រះជាម្ចាស់ជារៀងរាល់ថ្ងៃដែរឬទេ ? _____

សាវ័កប៉ូលសរសេរថា÷ «គ្រប់អត្ថបទគម្ពីរ សុទ្ធតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺអោយតែង និងមានប្រយោជន៍សំរាប់បង្រៀន រកខុសត្រូវ កែតម្រង់ និងអប់រំអោយរស់តាមសេចក្តីសុចរិត ក្នុងគោលបំណងអោយអ្នកបំរើរបស់ព្រះអម្ចាស់មានសមត្ថភាព និងប្រុងប្រៀបខ្លួនជាស្រេច ដើម្បីប្រព្រឹត្តអំពើល្អគ្រប់ជំពូក » ។ (២ ធីម៉ូថេ ៣:១៦-១៧)

សូមទន្ទេញខគម្ពីរជាច្រើនអោយចាំស្ទាត់ ។ ការធ្វើដូចនេះ ជួយអ្នកក្នុងការផ្សាយដំណឹងល្អពីព្រះគ្រីស្តប្រាប់អ្នកដទៃណាស់ ។ នៅក្នុងទំនុកតម្កើង ស្តេចដាវីឌមានបន្ទូលថា÷ «*ខ្ញុំលបង្គំរក្សាព្រះ-បន្ទូលរបស់ព្រះអង្គទុកនៅក្នុងចិត្ត ដើម្បីកុំអោយប្រព្រឹត្តអំពើបាបទាស់នឹងព្រះហឫទ័យព្រះអង្គ* » ។ (ទំនុកតម្កើង ១១៩:១១)

វិញដូច្នេះ ? គឺទាំងអ្នកស្រុកប៉ាថុស... ស្រុកមេឌី... ស្រុកអាស៊ី ស្រុកអេស៊ីប... ស្រុកលីប៊ី និងអស់អ្នកដែលមកពីក្រុងរ៉ូម..... ... យើងបានឮគេថ្លែងអំពីស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ជាភាសាយើងទាំងអស់គ្នាផ្ទាល់ ! » ។ អ្នកទាំងនោះងឿងឆ្ងល់ខ្លាំងណាស់ មិនដឹងគិតយ៉ាងណា គេសួរគ្នាទៅវិញទៅមកថា÷ «តើហេតុការណ៍នេះ មានន័យដូចម្តេច ? » ។ ប៉ុន្តែ មានអ្នកខ្លះទៀតបែរជានិយាយចំអកថា÷ «ពួកអស់ហ្នឹងសុទ្ធតែស្រវឹងស្រាទេតើ ! » ។

លោកពេត្រុសសិលាក៏ក្រោកឈរឡើងជាមួយគ្រីស្តទូតដប់មួយរូបទៀត ហើយមានប្រសាសន៍ទៅកាន់បណ្តាជនថា÷ «បងប្អូនយូដា និងបងប្អូនទាំងអស់ ដែលស្នាក់នៅក្រុងយេរូសាឡឹមអើយ ! សូមបងប្អូនជ្រាប ហើយផ្ទៀងត្រចៀកស្តាប់ពាក្យរបស់ខ្ញុំ ។ អ្នកទាំងនេះមិនមែនស្រវឹងស្រាដូចបងប្អូនស្មាននោះទេ ព្រោះទើបតែម៉ោងប្រាំបួនព្រឹកប៉ុណ្ណោះ ! ហេតុការណ៍នេះកើតមានស្របតាមសេចក្តីដែលព្យាការីយ៉ូអែលបានថ្លែងទុកមកថា÷ "ព្រះជាម្ចាស់មានព្រះបន្ទូលថា នៅគ្រាចុងក្រោយបង្អស់ យើងនឹងយកវិញ្ញាណយើងមកចាក់បង្ហូរលើមនុស្សលោកផងទាំងពួង"... ។

ហេតុនេះ សូមអោយជនជាតិអ៊ីស្រាអែលទាំងមូលដឹងជាក់ច្បាស់ ថា លោកយេស៊ូនេះ ដែលបងប្អូនបានឆ្កាង ព្រះជាម្ចាស់បាន តែងតាំងលោកឡើងជាព្រះអម្ចាស់ និងជាព្រះគ្រីស្តហើយ » ។ *កាលបណ្តាជនបានឮសេចក្តីទាំងនេះ ពួកគេរំជួលចិត្តជាខ្លាំង ហើយសួរលោកពេត្រុសសិលា និងគ្រីស្តជនឯទៀតៗថា÷«បងប្អូន អើយ ! តើអោយយើងខ្ញុំធ្វើដូចម្តេច ? »* ។

លោកពេត្រុសសិលាមានប្រសាសន៍ទៅគេថា÷ ***«សូមបងប្អូនកែប្រែចិត្តគំនិត ហើយម្នាក់ៗត្រូវទទួលពិធីជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូគ្រីស្តទៅ ដើម្បីអោយព្រះជាម្ចាស់លើកលែងទោសបងប្អូនអោយរួចពីបាប ហើយបងប្អូននឹងទទួលព្រះវិញ្ញាណដ៏វិសុទ្ធដែលជាអំណោយទានរបស់ព្រះជាម្ចាស់*** ។ *ដ្បិតព្រះអង្គមានព្រះបន្ទូលសន្យានេះចំពោះបងប្អូនទាំងអស់គ្នា ចំពោះកូនចៅរបស់បងប្អូន និងចំពោះអស់អ្នកដែលនៅឆ្ងាយៗទាំងប៉ុន្មានដែរ តាមតែព្រះអម្ចាស់ជាព្រះរបស់យើងត្រាស់ហៅ...»* ។ *អស់អ្នកដែលយល់ព្រមទទួលពាក្យរបស់លោក ក៏ទទួលពិធីជ្រមុជទឹក...*។

(កិច្ចការ ២)

តើពេលយើងអធិស្ឋានប្រចាំថ្ងៃ យើងត្រូវធ្វើអ្វីខ្លះ ?

☐ អរព្រះគុណ ។

☐ លន់តួសារភាពអំពើបាប និងអរព្រះគុណព្រះអង្គដែលបានអត់ទោសអោយយើង ។

☐ សរសើរដំកើង និងថ្វាយបង្គំ (យើងអាចនិយាយ ឬច្រៀងក៏បាន) ។

☐ ទូលអង្វរ (សំរាប់អ្នកដទៃ និងសំរាប់ខ្លួនឯង) ។

កិច្ចការទាំងនេះ ជាផ្នែកនៃការអធិស្ឋាន ។

នៅពេលដែលអារក្សល្បួងព្រះអម្ចាស់យេស៊ូគ្រីស្ត នៅទីវាលរហោស្ថាន ដោយទូលព្រះអង្គថា÷ *«ប្រសិនបើលោកពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន សូមធ្វើអោយដុំថ្មទាំងនេះទៅជានំបុ័ងមើល៍ !»* ព្រះយេស៊ូតបទៅវិញថា÷*«មនុស្សមិនមែនរស់ដោយសារអាហារប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ព្រះបន្ទូល ដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ដែរ »* ។

(ម៉ាថាយ ៤:៣-៤)

© Project WorldReach © SEAN

អ្នកខាងគណៈផារីស៊ីអធិស្ឋានដោយអំនួត មិនមែនដោយជំនឿ ទេ ។ អ្នកទារពន្ធបន្ទាបខ្លួននៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ ។

តើយើងគួរអធិស្ឋានដោយរបៀបណា ដើម្បីអោយបានចូលទៅក្នុងវត្តមានរបស់ព្រះជាម្ចាស់ ? តើយើងត្រូវចូលទៅជិតស្តេចលើអស់ទាំងស្តេច ដោយរបៀបណា ?

☐ ទូលដោយទទូចអំពីសេចក្តីត្រូវការរបស់យើង ដូចសត្វតោ។

☐ ស្លូតបូតទាំងបន្ទាបខ្លួន ដូចសត្វចៀម ។

ព្រះយេស៊ូមានព្រះបន្ទូលថា អ្នកណាលើកខ្លួនឯងជាធំ នឹងត្រូវបន្ទាបចុះ ឯអ្នកដែលបន្ទាបខ្លួន នឹងត្រូវលើកឡើង ។

តើព្រះជាម្ចាស់ស្តាប់ការអធិស្ឋានមួយណា ?

☐ ការប្រកាសដោយអំនួតរបស់បុរសម្នាក់ខាងគណៈផារីស៊ី ។

☐ ការអធិស្ឋានដោយបន្ទាបខ្លួនរបស់បុរសម្នាក់ ដែលមានបាប ។

ព្រះជាម្ចាស់ឮអ្នកមានបាប ដែលទូលសូមអោយព្រះអង្គលើកលែងទោស ។

នៅក្នុងផ្នែកដំបូងនៃអត្ថបទនេះ យើងឃើញព្រះជាម្ចាស់ប្រទានពរដល់ពួកសាវ័ក ដោយបំពេញពួកគេ ដោយព្រះវិញ្ញាណដ៏វិសុទ្ធ ។ ព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះជាម្ចាស់ផ្ទាល់ ដែលមានគួនាទីមកគង់សណ្ឋិតក្នុងបុត្រធីតារបស់ព្រះជាម្ចាស់ **ធ្វើជាត្រាសញ្ញាបញ្ជាក់ថាពួកគេជាបុត្រធីតារបស់ព្រះអង្គពិត និងប្រទានអោយពួកគេមានកំឡាំង**អាចទប់ទល់នឹងមារសាតាំងបាន **ឱ្យពួកគេមានឫទ្ធានុភាព** មាន**ព្រះអំណោយទាន** និងមាន**ផលផ្លែ**ដើម្បីបំរើព្រះអង្គ ។

តើអ្នកបានទទួលអំណោយទានរបស់ព្រះជាម្ចាស់ ដែលជាព្រះវិញ្ញាណដ៏វិសុទ្ធ នៅក្នុងជីវិតរបស់អ្នកហើយឬនៅ ?

នៅក្នុងផ្នែកចុងក្រោយនៃអត្ថបទសំរាប់អានខាងលើនេះ តើសាវ័កពេត្រុសប្រាប់មនុស្សអោយធ្វើដូចម្តេច ដើម្បីអោយបានសង្គ្រោះ ?

© Project WorldReach © SEAN

សូមពិនិត្យមើលអំពីសេចក្តី ដែលលោកពេត្រុសបានប្រាប់ឱ្យធ្វើ ។

១- កែប្រែចិត្តគំនិត បែរមករកព្រះជាម្ចាស់វិញ

លោកពេត្រុសប្រាប់យើងអោយកែប្រែចិត្តគំនិត ។ បានសេចក្តីថា ត្រូវងាកចេញពីអំពើបាប ហើយកែប្រែចិត្តគំនិត ។ ព្រះជាម្ចាស់ជួយយើងអោយអាចបែរចេញពីអំពើបាប ហើយមកបំរើព្រះអង្គវិញ ។

២- ទទួលពិធីជ្រមុជទឹក

លោកពេត្រុសអញ្ជើញយើងអោយទទួលពិធីជ្រមុជទឹក ។ បទគម្ពីរ៉ូម ចំពូក ៦ បានបង្ហាញថា ពិធីជ្រមុជទឹកបញ្ជាក់ពីកិច្ចការពីយ៉ាង ទីមួយ យើងបានស្លាប់រួមជាមួយព្រះគ្រីស្ត គឺយើងស្លាប់ពីអំពើបាបរបស់យើង ហើយទីពីរ យើងរស់ឡើងវិញជាមួយព្រះគ្រីស្ត ដែលធ្វើអោយយើងមានជីវិតថ្មី និង វិសុទ្ធ ។

«...យើងទាំងអស់គ្នា ដែលបានទទួលពិធីជ្រមុជទឹក ដើម្បីរួមជាមួយព្រះគ្រីស្តយេស៊ូនោះ គឺយើងបានជ្រមុជរួមជាមួយព្រះអង្គដែលសោយទីវង្គត » ។

(រ៉ូម ៦:៣)

រីឯអ្នកទារពន្ធ គាត់ឈរនៅពីចម្ងាយ មិនទាំងហ៊ានងើបមុខផង ។ គាត់គក់ទ្រូងទួលថា "ឱព្រះជាម្ចាស់អើយ ! សូមអាណិតមេត្តាទួលបង្គំជាមនុស្សបាបផង" ។ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់ប្រោសអ្នកទារពន្ធនេះអោយបានសុចរិត ហើយគាត់ត្រឡប់ទៅផ្ទះវិញ រីឯបុរសខាងគណៈផារីស៊ីមិនបានសុចរិតទេ ។ អ្នកណាលើកតម្កើងខ្លួន អ្នកនោះនឹងត្រូវគេបន្ទាបចុះ រីឯអ្នកដែលបន្ទាបខ្លួននឹងត្រូវគេលើកតម្កើងវិញ » ។

(លូកា ១៨:១-១៤)

ស្ត្រីមេម៉ាយនៅតែបន្តព្យាយាមអង្វរចៅក្រមអោយជួយនាង ។ ១ ថែស្សាឡូនិក ៥:១៧ ជំរុញយើងឱ្យអធិស្ឋាន *«គ្រប់ពេល»* ។ នៅក្នុងសេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់ ព្រះគ្រីស្តបង្រៀនយើងអោយទូលសូមអោយមានចំណីអាហារប្រចាំថ្ងៃ ។

តើអ្នកខិតខំអធិស្ឋានទៅព្រះជាម្ចាស់ រាល់ថ្ងៃដែរឬទេ ? _____

តើអ្នកយល់ព្រមអធិស្ឋានជាមួយក្រុមគ្រួសាររបស់អ្នក រាល់ថ្ងៃដែរឬទេ ? _____

ពិធីជ្រមុជទឹកជាទីសំគាល់បញ្ជាក់អោយពួកគ្រីស្តជនដឹងថា គេបានស្លាប់រួមជាមួយព្រះគ្រីស្តពីអំពើបាប ហើយមានជីវិតរស់ឡើងវិញរួមជាមួយព្រះអង្គ នៅចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ។

«ដូច្នេះ ប្រសិនបើយើងរួមស្លាប់ជាមួយព្រះគ្រីស្ត យើងក៏ជឿថាយើងនឹងមានជីវិតរួមជាមួយព្រះអង្គដែរ » ។

(រ៉ូម ៦:៨)

៣- ទទួលព្រះវិញ្ញាណដ៏វិសុទ្ធ

យើងត្រូវទុកឱ្យព្រះជាម្ចាស់ធ្វើការក្នុងចិត្តរបស់យើងចុះ ។ លោកពេត្រុសបានសន្យានឹងពួកអ្នកជឿថ្មី ដែលបានកែប្រែចិត្តគំនិតថា គេនឹងបានទទួលព្រះអំណោយទានជាព្រះ-វិញ្ញាណដ៏វិសុទ្ធ ។ យើងចាប់ផ្តើមជីវិតថ្មីក្នុងព្រះគ្រីស្ត (គឺយើងបានកើតជាថ្មី) ដោយសារកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់សណ្ឋិតក្នុងយើង ។ យើងអាចទទួលព្រះវិញ្ញាណដ៏វិសុទ្ធបាន ដោយសារជំនឿ (យ៉ូហាន ១៤:១៦-១៨, កាឡាទី ៣:១-៦) ។

ព្រះអង្គរឹតតែរកយុត្តិធម៌អោយអស់អ្នកដែលព្រះអង្គបានជ្រើសរើស ហើយដែលអង្វរព្រះអង្គទាំងយប់ទាំងថ្ងៃ ព្រះអង្គគ្រាន់តែបង្អង់ប៉ុណ្ណោះ ។ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះអង្គនឹងរកយុត្តិធម៌អោយគេក្នុងរយៈពេលដ៏ខ្លី ។ ប៉ុន្តែ ពេលបុត្រមនុស្សមកដល់ តើលោកឃើញមនុស្សមានជំនឿនៅលើផែនដីនេះឬទេ ? » ។

ព្រះអង្គមានព្រះបន្ទូលជាប្រស្នាមួយទៀត ទៅកាន់អ្នកខ្លះដែលនឹកស្មានថា ខ្លួនជាមនុស្សសុចរិត ហើយបែរជាមើលងាយអ្នកដទៃ ។ ព្រះអង្គមានព្រះបន្ទូលថា÷ «មានបុរសពីរនាក់ឡើងទៅអធិស្ឋានក្នុងព្រះវិហារ ។ ម្នាក់ខាងគណៈផារីស៊ី ម្នាក់ទៀតជាអ្នកទារពន្ធ។ បុរសខាងគណៈផារីស៊ីឈរអធិស្ឋានក្នុងចិត្តថា"បពិត្រព្រះជាម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ព្រោះទូលបង្គំមិនដូចជនឯទៀតៗទេ អ្នកទាំងនោះសុទ្ធតែជាចោរ ជាមនុស្សទុច្ចរិត ជាមនុស្សប្រព្រឹត្តអំពើផិតក្បត់ ហើយទូលបង្គំក៏មិនដូចអ្នកទារពន្ធនេះដែរ ទូលបង្គំតមអាហារពីរដងក្នុងមួយអាទិត្យ ហើយទូលបង្គំថ្វាយរបស់អ្វីៗទាំងអស់ ដែលទូលបង្គំរកបានមួយភាគដប់ដល់ព្រះអង្គ " ។

«ដូច្នេះ បើបងប្អូនបានទទួលព្រះគ្រីស្តយេស៊ូទុកជា ព្រះអម្ចាស់យ៉ាងណាហើយ ចូររស់នៅរួមជាមួយព្រះអង្គ យ៉ាងនោះតទៅទៀតទៅ » ។ *(កូឡូស ២:៦)*

ការរស់រួមជាមួយព្រះយេស៊ូមានន័យថា យើងទុកអោយ ព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំជីវិតរបស់យើង ពេលដែលយើង ធ្វើតាមគំរូរបស់ព្រះយេស៊ូកាន់តែខ្លាំងឡើងៗ ។

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានទូលសូមឱ្យព្រះជាម្ចាស់បំពេញអ្នក និងដឹកនាំអ្នក តាមរយៈបុទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។
- សូមចែកចាយមេរៀននេះប្រាប់ដល់សាច់ញាតិរបស់អ្នក ដោយប្រើរូបភាព និងពន្យល់ពីចំណុចទាំង ៣ ដែល សាវ័កពេត្រុសបានបញ្ជាក់ប្រាប់ ហើយអញ្ជើញសាច់ញាតិ ទាំងនោះ អោយបែរមករកព្រះជាម្ចាស់ ទទួលពិធីជ្រមុជទឹក និងទទួលព្រះពរជាព្រះវិញ្ញាណដ៏វិសុទ្ធដែរ ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

អធិស្ឋាន និង រិះគិតពិចារណាពីព្រះបន្ទូលព្រះជាម្ចាស់ ដោយជំនឿ ជារៀងរាល់ថ្ងៃ

បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលជាប្រស្នាពន្យល់សាវ័កអោយ ដឹងថា ត្រូវតែអធិស្ឋានជានិច្ចមិនត្រូវរសាយចិត្តឡើយ ។

«នៅក្នុងក្រុងមួយ មានចៅក្រមម្នាក់ជាមនុស្សមិនកោតខ្លាច ព្រះជាម្ចាស់ ហើយមិនកោតក្រែងនរណាឡើយ ។ មានស្ត្រី មេម៉ាយម្នាក់នៅក្នុងក្រុងនោះដែរ គាត់តែងមកអង្វរចៅក្រមថា សូមលោករកយុត្តិធម៌អោយនាងខ្ញុំផង" ។ ប៉ុន្តែ ចៅក្រមមិន ព្រមកាត់ក្តីអោយភ្លាមៗទេ លោកចេះតែពន្យារពេលយ៉ាងយូរ ។ ក្រោយមក លោកនឹកក្នុងចិត្តថា "ទោះបីអញមិនកោតខ្លាច ព្រះជាម្ចាស់ មិនកោតក្រែងនរណាក៏ដោយ ក៏អញត្រូវតែកាត់ក្តី អោយស្ត្រីមេម៉ាយនេះដែរ ព្រោះគាត់ចេះតែមករំអុកអញគ្រប់ ពេលវេលា ។ បើអញមិនកាត់ក្តីអោយគាត់ទេ មុខជាគាត់មក រំខានអញមិនចេះចប់មិនចេះហើយ" » ។

ព្រះអម្ចាស់មានព្រះបន្ទូលបន្ថែមទៀតថា÷ «ចូរពិចារណាពាក្យ របស់ចៅក្រមដ៏អាក្រក់នេះចុះ ។ ចំណង់បើព្រះជាម្ចាស់វិញ

អត្ថបទសិក្សា ទី ៣

ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត



អត្ថបទសិក្សា ទី ៥

ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត



ចូរស្រឡាញ់ព្រះជាម្ចាស់ អ្នករួមជំនឿជាមួយអ្នក អ្នកជិតខាង និងសត្រូវរបស់អ្នក

ពេលនោះមានបណ្ឌិតខាងវិន័យម្នាក់ក្រោកឈរ ទូលសួរព្រះយេស៊ូ ក្នុងគោលបំណងចង់ចាប់កំហុសព្រះអង្គថា៖ «លោកគ្រូ ! តើខ្ញុំ ត្រូវធ្វើអ្វីខ្លះ ដើម្បីអោយបានទទួលជីវិតអស់កល្បជានិច្ច ? » ។

ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «តើក្នុងគម្ពីរវិន័យមានចែងទុកមកដូចម្តេចខ្លះ ? ពេលលោកអាន តើលោកយល់យ៉ាងណា ? » ។

គាត់ទូលឆ្លើយទៅព្រះយេស៊ូថា៖ «ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកអោយអស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីកម្លាំង និងអស់ពីប្រាជ្ញា ហើយត្រូវស្រឡាញ់បងប្អូនឯទៀតៗ អោយបានដូចស្រឡាញ់ខ្លួនឯងដែរ » ។

ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «លោកឆ្លើយត្រឹមត្រូវល្អណាស់ សុំធ្វើដូច្នេះទៅ នោះលោកនឹងមានជីវិតអស់កល្បជាមិនខាន» ។ ប៉ុន្តែ បណ្ឌិតខាងវិន័យនោះចង់បង្ហាញថា សំណួររបស់គាត់ជាសំណួរត្រឹមត្រូវ គាត់ក៏សួរព្រះយេស៊ូទៀតថា៖ «តើនរណាជាបងប្អូនរបស់ខ្ញុំ ? » ។

សូមទន្ទេញ

«បន្ទាប់មក ព្រះអង្គយកនំបុ័ងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចព្រះអង្គកាច់ប្រទានអោយគេ ទាំងមានព្រះបន្ទូលថា៖ "នេះជារូបកាយខ្ញុំ ដែលត្រូវបូជាសំរាប់អ្នករាល់គ្នា ចូរធ្វើដូច្នេះ ដើម្បីនឹករំឭកដល់ខ្ញុំ" » ។

(លូកា ២២:១៩)

កិច្ចការដែលត្រូវអនុវត្ត

- ចូលរួមធ្វើពិធីកាច់នំបុ័ងជាមួយក្រុមជំនុំរបស់អ្នកជានិច្ច ហើយរួមចិត្តគំនិតជាមួយព្រះគ្រីស្តជារៀងរាល់ថ្ងៃ ។
- និយាយប្រាប់ក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នក អំពីប្រស្នាស្តីអំពីដើមទំពាំងបាយជូរ ដោយប្រើរូបភាពបំភ្លឺ ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

© Project WorldReach © SEAN

យើងត្រូវរំលឹកឡើងវិញអំពីសេចក្តីបង្គាប់សំខាន់ៗទាំងប្រាំពីររបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត សំរាប់ពួកសិស្សរបស់ព្រះអង្គ :

១- ចូរនាំគ្នាកែប្រែចិត្តគំនិត ហើយជឿជំណឹងល្អចុះ ។ ចូរទទួលព្រះវិញ្ញាណ (ម៉ាកុស ១:១៥, យ៉ូហាន ២០:២២) ។

២- ទទួលពិធីជ្រមុជទឹក (ម៉ាថាយ ២៨:១៩) ។

៣- ត្រូវមានសេចក្តីស្រឡាញ់ (ម៉ាថាយ ២២:៣៧-៣៩) ។

៤- ចូលរួមធ្វើពិធីកាច់នំប៉័ង (លូកា ២២:១៩-២០) ។

៥- អធិស្ឋាន និងរិះគិតពិចារណាពីព្រះបន្ទូលព្រះជាម្ចាស់ (ម៉ាថាយ ៦:៩-១៣) ។

៦- ធ្វើអំណោយ (លូកា ៦:៣៨) ។

៧- បង្កើតសាវ័ក (ម៉ាថាយ ២៨:១៩) ។

តើសេចក្តីបង្គាប់ណាមួយដែលសំខាន់ជាងគេ ? _____

ព្រះយេស៊ូមានបន្ទូលថា៖ « *ប្រសិនបើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ អ្នករាល់គ្នាពិតជាកាន់តាមវិន័យរបស់ខ្ញុំ* » ។

(យ៉ូហាន ១៤:១៥)

ព្រះយេស៊ូមានព្រះបន្ទូលថា៖ « មានបុរសម្នាក់ធ្វើដំណើរចុះពីក្រុងយេរូសាឡឹម ឆ្ពោះទៅក្រុងយេរីខូ ។ គាត់ធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ពួកចោរ វាប្លន់គាត់ ថែមទាំងវាយដំគាត់អោយរបួសជាទម្ងន់ រួចនាំគ្នារត់បាត់អស់ទៅ ទុកគាត់ចោលនៅស្តូកស្តឹង បាត់ស្មារតីមិនដឹងខ្លួន ។

ពេលនោះ មានបូជាចារ្យមួយរូបធ្វើដំណើរចុះតាមផ្លូវនោះ ។ គាត់ឃើញបុរសនោះ ក៏ដើរវាងហួសទៅ ។ មានម្នាក់ពីក្រុមលេវីដើរមកដល់កន្លែងនោះដែរ គាត់ឃើញបុរសនោះ ក៏ដើរវាងហួសទៅ ។

គាប់ជួនជាមានអ្នកស្រុកសាម៉ារីម្នាក់ ធ្វើដំណើរមកតាមផ្លូវនោះដែរ គាត់ឃើញបុរសនោះ គាត់មានចិត្តអាណិតអាសូរពន់ពេកណាស់ ។ គាត់ចូលទៅជិតអ្នករបួសយកប្រេង និងស្រាចាក់ពីលើមុខរបួស រុំរបួសអោយ រួចគាត់លើកអ្នករបួសដាក់លើជំនិះរបស់គាត់ នាំទៅផ្ទះសំណាក់ ហើយថែទាំអ្នករបួសនោះ ។

ស្អែកឡើង គាត់យកប្រាក់ប្រគល់អោយម្ចាស់ផ្ទះសំណាក់ទាំងផ្តាំថា "សូមថែទាំបុរសនេះផង ប្រសិនបើអ្នកចំណាយលើសពីប្រាក់នេះ ពេលខ្ញុំត្រឡប់មកវិញ ខ្ញុំនឹងជូនបង្គ្រប់" » ។

ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ក្នុងចំណោមមនុស្សទាំង បីនាក់ តើលោកយល់ថា អ្នកណាចាត់ទុកខ្លួនជាបងប្អូននឹងបុរស ដែលធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ពួកចោរប្លន់នោះ ? » ។

បណ្ឌិតខាងវិន័យឆ្លើយថា៖ «គឺអ្នកដែលមានចិត្តមេត្តាករុណា ចំពោះគាត់» ។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «សុំលោក អញ្ជើញទៅចុះ ហើយប្រព្រឹត្តអោយបានដូចអ្នកនោះទៅ » ។

(លូកា ១០:២៥-៣៧)

សាវ័កប៉ូលពន្យល់ថា សេចក្តីស្រឡាញ់នាំអោយអាចប្រតិបត្តិតាម វិន័យគ្រប់យ៉ាងរបស់ព្រះជាម្ចាស់បានពេញលក្ខណៈ :

ព្រោះវិន័យដែលចែងថា៖«កុំប្រព្រឹត្តអំពើផិតក្បត់ កុំសម្លាប់មនុស្ស កុំលួចទ្រព្យសម្បត្តិគេ កុំមានចិត្តលោភលន់ » និងវិន័យឯទៀតៗ សង្ខេបមកជាវិន័យតែមួយនេះថា៖ «ចូរស្រឡាញ់បងប្អូនឯទៀតៗ អោយបាន ដូចស្រឡាញ់ខ្លួនឯងដែរ »។ អ្នកមានចិត្តស្រឡាញ់ មិនដែលប្រព្រឹត្តអាក្រក់ដល់បងប្អូនឯទៀតឡើយ ។ ដូច្នេះ សេចក្តីស្រឡាញ់នាំអោយប្រតិបត្តិតាមវិន័យបានពេញលក្ខណៈ ។

(រ៉ូម ១៣:៩-១០)

ពិធីកាច់នំប៉័ងតំណាងការរួមចិត្តគំនិតរបស់យើងជាមួយព្រះគ្រីស្ត ដោយសារព្រះគ្រីស្ត (១ កូរិនថូស ១០:១៦-១៧) ។ យើងនឹងធ្វើឱ្យការរួមចិត្តគំនិតគ្នានេះនៅស្ថិតស្ថេរ ដោយធ្វើតាមសេចក្តីបង្គាប់របស់ព្រះអង្គ ។

ព្រះគ្រីស្តមានបន្ទូលថា ព្រះអង្គជាដើមទំពាំងបាយជូរ ឯយើងជាមែក ។ យោងទៅតាមព្រះបន្ទូល តើយើងត្រូវធ្វើដូចម្តេច ដើម្បីបង្កើតផលផ្លែអោយបានច្រើន ?

_____

_____

បើសិនជាយើងមិននៅជាប់នឹងព្រះអង្គទេ តើនឹងមានការអ្វីកើតឡើង ?

_____

_____

ផលផ្លែដែលយើងបង្កើត ជាលទ្ធផលនៃការប្រតិបត្តិតាមព្រះ-ជាម្ចាស់ ដោយសេចក្តីស្រឡាញ់ ។

© Project WorldReach © SEAN

« ហេតុនេះ ប្រសិនបើអ្នកណាពិសានំបុ័ង និងពិសាពីពែងរបស់ព្រះអម្ចាស់ដោយមិនសមរម្យ អ្នកនោះនឹងមានកំហុស ដោយមិនបានគោរពព្រះកាយ និងព្រះលោហិតរបស់ព្រះអម្ចាស់ ។ ដូច្នេះ ម្នាក់ៗត្រូវពិនិត្យពិច័យមើលចិត្តគំនិតរបស់ខ្លួនឯងសិន សឹមពិសានំបុ័ង និងពិសាពីពែងរបស់ព្រះអម្ចាស់ ដ្បិតអ្នកណាពិសានំបុ័ង និងពិសាពីពែងនោះ ដោយមិនបានយល់ដល់ព្រះកាយរបស់ព្រះអម្ចាស់ទេ អ្នកនោះយកទោសមកដាក់លើខ្លួនឯងផ្ទាល់ » ។

(១ កូរិនថូស ១១:២៣-២៩)

តើនៅក្នុងពិធីកាច់នំបុ័ង នំបុ័ងតំណាងអ្វី ?

_____

ឯពែងទឹកទំពាំងបាយជូរ តំណាងអ្វីដែរ ?

_____

យោងទៅតាមអត្ថបទព្រះគម្ពីរដែលយើងបានអាន ដើម្បីចូលរួមធ្វើពិធីកាច់នំបុ័ងអោយបានត្រឹមត្រូវ តើយើងត្រូវធ្វើដូចម្តេច មុននឹងទទួលយកនំបុ័ង និងទឹកទំពាំងបាយជូរ ?

_____

ព្រះយេស៊ូ និងពួកសាវ័កព្រះអង្គ បានធ្វើអោយឃើញតាមរយៈពាក្យសំដី និងការប្រព្រឹត្តរបស់ពួកលោកថា សេចក្តីស្រឡាញ់មានសារៈសំខាន់ខ្លាំងបំផុត ។ ជាដំបូង យើងត្រូវស្រឡាញ់ព្រះជាម្ចាស់ បន្ទាប់មក យើងត្រូវស្រឡាញ់មនុស្សទាំងអស់ ។

តើអ្នកចង់ធ្វើតាមវិន័យសំខាន់ទាំងពីរនេះដែរឬទេ ?_____

សេចក្តីស្រឡាញ់ពិត ជាផលផ្លែរបស់ព្រះវិញ្ញាណព្រះជាម្ចាស់ នៅក្នុងចិត្តរបស់យើង ។ មានតែគ្រីស្តជនដែលពេញដោយព្រះ-វិញ្ញាណដ៏វិសុទ្ធទេ ដែលអាចស្រឡាញ់សត្រូវរបស់ខ្លួនបាន គឺថាស្រឡាញ់ពួកអ្នកដែលធ្វើអោយខ្លួនឈឺចាប់ និងធ្វើអាក្រក់មកលើខ្លួន ។ មានតែព្រះជាម្ចាស់ទេ ដែលអាចធ្វើអោយយើងមានសេចក្តីស្រឡាញ់លះបង់ដូចនេះបាន ។ នៅក្នុងអេភេសូ ៤:៣២ សាវ័កប៉ូលបង្គាប់យើងថា៖*« ត្រូវមានចិត្តសប្បុរស និងចេះអាណិតមេត្តាដល់គ្នាទៅវិញទៅមក ។ ត្រូវប្រណីសន្តោសគ្នាទៅវិញទៅមក ដូចព្រះជាម្ចាស់បានប្រណីសន្តោសបងប្អូន ដោយសារព្រះ-គ្រីស្តដែរ » ។*

តើអ្នកនឹងធ្វើដូចម្តេច ដើម្បីអត់ទោស និងបង្ហាញក្តីស្រឡាញ់ចំពោះមនុស្សដែលបានធ្វើអាក្រក់មកលើអ្នក ?
(សូមគិតពីស្ថានភាពពិតមួយ) ។

តើអ្នកអាចធ្វើដូចម្តេច ដើម្បីបង្ហាញថា អ្នកកាន់តែស្រឡាញ់គ្រួសារអ្នកខ្លាំងឡើងៗ ? (កិច្ចការមួយដែលត្រូវអនុវត្ត) ។

បើអ្នករាល់គ្នាស្ថិតនៅជាប់នឹងខ្ញុំ ហើយបើពាក្យខ្ញុំស្ថិតនៅជាប់នឹងអ្នករាល់គ្នា ចូរទូលសុំអ្វីៗតាមតែអ្នករាល់គ្នាប្រាថ្នាចង់បានចុះ នោះអ្នករាល់គ្នាមុខតែបានទទួលជាមិនខាន ។ ព្រះបិតារបស់ខ្ញុំសំដែងសិរីរុងរឿង ដោយអ្នករាល់គ្នាបង្កើតផលផ្លែបានច្រើន និងដោយអ្នករាល់គ្នាជាសិស្សរបស់ខ្ញុំមែន » ។

(យ៉ូហាន ១៥:១-៨)

(សាវ័កប៉ូលមានប្រសាសន៍ថា) «*រីឯខ្ញុំ ខ្ញុំបានជំរាបបងប្អូនអ្វីសេចក្តីដែលខ្ញុំបានទទួលពីព្រះអម្ចាស់មកថា នៅយប់ដែលព្រះអម្ចាស់យេស៊ូត្រូវគេចាប់បញ្ជូនទៅឆ្កាង ព្រះអង្គយកនំប៉័ងមកកាន់ ទ្រង់អរព្រះគុណព្រះជាម្ចាស់ ហើយកាច់នំប៉័ងនោះ ទាំងមានព្រះបន្ទូលថា÷ "នេះជារូបកាយខ្ញុំ ដែលត្រូវបូជាសំរាប់អ្នករាល់គ្នា ។ ចូរធ្វើដូច្នេះ ដើម្បីរំឭកដល់ខ្ញុំ" ។ លុះជប់លៀងរួចហើយ ព្រះអង្គធ្វើតាមបែបដដែល ទ្រង់យកពែងមកកាន់ទាំងមានព្រះបន្ទូលថា "នេះជាពែងនៃសម្ពន្ធមេត្រីថ្មី ចងឡើងដោយលោហិតរបស់ខ្ញុំ ។ គ្រប់ពេលដែលអ្នករាល់គ្នាពិសា ចូរធ្វើដូច្នេះដើម្បីរំឭកដល់ខ្ញុំ" ។ រៀងរាល់ពេលដែលបងប្អូនពិសានំប៉័ង និងពិសាពីពែងនេះ បងប្អូនប្រកាសអំពីព្រះអម្ចាស់សោយទិវង្គតរហូតដល់ព្រះអង្គយាងមកវិញ»*។

© Project WorldReach © SEAN

ត្រូវចូលរួមធ្វើពិធីជប់ល្បែងរបស់ព្រះអម្ចាស់
(ពិធីកាច់នំបុ័ង)

ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំហ្នឹងហើយជាដើមទំពាំងបាយជូរ ដ៏ពិតប្រាកដ រីឯព្រះបិតាខ្ញុំ ជាម្ចាស់ចំការ ។ មែកណានៅជាប់នឹងខ្ញុំ តែឥតមានផ្លែ ព្រះបិតាកាត់មែកនោះចោល ។ រីឯមែកណាមានផ្លែ ព្រះអង្គលួសមែកនោះ ដើម្បីអោយមានផ្លែកាន់តែច្រើនឡើងទៀត ។ ពាក្យដែលខ្ញុំបានប្រាប់ ធ្វើអោយអ្នករាល់គ្នាបរិសុទ្ធរួចទៅហើយ ។ ចូរស្ថិតនៅជាប់នឹងខ្ញុំ ដូចខ្ញុំស្ថិតនៅជាប់នឹងអ្នករាល់គ្នាដែរ ។ ប្រសិនបើមែកមិនស្ថិតនៅជាប់នឹងដើមទេ វាពុំអាចបង្កើតផលដោយឯកឯងបានឡើយ ។ រីឯអ្នករាល់គ្នាក៏ដូច្នោះដែរ បើមិនស្ថិតនៅជាប់នឹងខ្ញុំទេ អ្នករាល់គ្នាពុំអាចបង្កើតផលបានទាល់តែសោះ ។

ខ្ញុំនេះហើយជាដើមទំពាំងបាយជូរ អ្នករាល់គ្នាជាមែក អ្នកណាស្ថិតនៅជាប់នឹងខ្ញុំ ហើយខ្ញុំនៅជាប់នឹងអ្នកនោះ ទើបអ្នកនោះបង្កើតផលបានច្រើន ។ បើដាច់ពីខ្ញុំ អ្នករាល់គ្នាពុំអាចធ្វើអ្វីកើតឡើយ ។ អ្នកណាមិនស្ថិតនៅជាប់នឹងខ្ញុំ អ្នកនោះប្រៀបដូចជាមែកដែលគេបោះចោលទៅខាងក្រៅ ហើយស្វិតក្រៀម ។ បន្ទាប់មក គេរើសមែកទាំងនោះបោះទៅក្នុងភ្លើងឆេះអស់ទៅ ។

នៅក្នុងយ៉ូហាន ១៤:១៥ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ប្រសិនបើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ អ្នករាល់គ្នាពិតជាកាន់តាមវិន័យរបស់ខ្ញុំ» ។ នៅក្នុងសេចក្តីស្រឡាញ់ មានក្រិត្យវិន័យគ្រប់យ៉ាងទាំងអស់ (រ៉ូម ១៣:៩) ។ អ្នកដែលស្រឡាញ់ព្រះជាម្ចាស់ និយាយតែការពិតប៉ុណ្ណោះ (មិននិយាយភរទេ) ធ្វើកិច្ចការដោយសុចរិត (មិនដែលលួច) មានជីវិតបរិសុទ្ធ (មិនដែលផិតក្បត់) ស្កប់ចិត្តនឹងអ្វីៗដែលព្រះជាម្ចាស់ប្រទានអោយ (គ្មានចិត្តលោភចង់បានរបស់អ្នកដទៃ) ។ល។...។

តើអ្នកធ្វើដូចម្តេច ដើម្បីបង្ហាញថាអ្នកស្រឡាញ់ព្រះយេស៊ូគ្រីស្តដោយស្មោះ ? (កិច្ចការពិសេសមួយ ដើម្បីថ្វាយសិរីល្អដល់ព្រះអង្គ) ។

សូមទន្ទេញ

«ព្រះយេស៊ូមានព្រះបន្ទូលថា៖ "ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកអោយអស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញាហ្នឹងហើយជាវិន័យទីមួយដែលសំខាន់ជាងគេបំផុត ។ រីងវិន័យទីពីរក៏សំខាន់ដូចគ្នាដែរ គឺត្រូវស្រឡាញ់បងប្អូនឯទៀតៗអោយបានដូចស្រឡាញ់ខ្លួនឯង" » ។

(ម៉ាថាយ ២២:៣៧-៣៩)

កិច្ចការដែលត្រូវអនុវត្ត

- ចាប់ផ្តើមធ្វើអ្វីមួយ ដែលបង្ហាញពីសេចក្តីស្រឡាញ់របស់អ្នក (កិច្ចការជាក់ស្តែងមួយ ដែលមានប្រយោជន៍ ដែលអ្នកមិនទាន់បានធ្វើពីមុនមក) ចំពោះគ្រួសារ ឬ មិត្តភក្តិខ្លះ ឬ សត្រូវរបស់អ្នក ។
- និយាយរឿងអំពីអ្នកស្រុកសាម៉ារី ដែលមានចិត្តសប្បុរសប្រាប់គ្រួសាររបស់អ្នក ដោយប្រើរូបភាពបំភ្លឺ ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

អត្ថបទសិក្សា ទី ៤

ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត



© Project WorldReach © SEAN